- យោងលិខិតលេខ១៦៥០ សហវ.វស ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១._**

ត្រូវបានបង្កើតអង្គភាពគ្រប់គ្រងកម្មវិធីថ្នាក់ជាតិ (National Implementation Office-NIO) នៃកម្មវិធីអភិវឌ្ឍន៍ពាណិជ្ជកម្មស្រូវដែលធន់នឹងអាកាសធាតុ (Rice-SDP) ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **គិត សេខ** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | នាយកគ្រប់គ្រងកម្មវិធី |
| ២. | ឯកឧត្តម **ខិន ឆាយ** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម | នាយករងគ្រប់គ្រងកម្មវិធី |
| ៣. | លោក **អោម ពេជ្រ** | អនុប្រធានន.ការពារដំណាំ អនាម័យ និងភូតគាមអនាម័យ | មន្ត្រីសម្របសម្រួលកម្មវិធី |
| ៤. | លោកស្រី **អ៊ុន សុភា** | អនុប្រធានការិ.នៃន.រដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ | មន្ត្រីទទួលបន្ទុករដ្ឋបាល គណនេយ្យហិរញ្ញវត្ថុ |
| ៥. | លោក **ញ៉ៀប ចាន់** | ប្រធានការិ.នៃន.ការពារដំណាំ អនាម័យ និងភូតគាមអនាម័យ | មន្ត្រីទទួលបន្ទុកផែនការ និងការអនុវត្តគម្រោង |
| ៦. | លោកស្រី **គន្ធ ច័ន្ទម៉ាណាត់** | មន្ត្រីនៃន.ការពារដំណាំ អនាម័យ និងភូតគាមអនាម័យ | មន្ត្រីរដ្ឋបាល |
| ៧. | លោក **ឃី រតនៈ** | អនុប្រធានការិ.នៃន.វិស្វកម្មកសិកម្ម | មន្ត្រីទទួលបន្ទុកគ្រប់គ្រងកិច្ចសន្យា |
| ៨. | លោក **អំ តិរម្យ** | អនុប្រធានន.គ្រប់គ្រងធនធានដីកសិកម្ម | មន្ត្រីទទួលបន្ទុកគ្រប់គ្រងធនធានដី |
| ៩. | លោក **ជា សុវណ្ណឌីណា** | អនុប្រធានន.វិស្វកម្មកសិកម្ម | មន្ត្រីទទួលបន្ទុកបច្ចេកវិទ្យាមុន និងក្រោយពេលប្រមូលផល |
| ១០. | លោក **ស៊ុន ទ្រី** | ប្រធានការិ.នៃន.ផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | មន្ត្រីទទួលបន្ទុកការងារផ្សព្វផ្សាយកសិកម្ម |
| ១១. | លោក **ពេជ ផល្លី** | ប្រធានការិ.នៃនាយកដ្ឋានដំណាំស្រូវ | មន្ត្រីទទួលបន្ទុកបច្ចេកទេសដំណាំស្រូវ |
| ១២. | លោកស្រី **រស់ វ៉ា** | អនុប្រធានការិ.នៃន.ដំណាំស្រូវ | មន្ត្រីទទួលបន្ទុកយេនឌ័រ និងបម្រែបម្រួលអាកាសធាតុ |
| ១៣. | លោក **យាវ ពុទ្ធី** | មន្ត្រីនៃនាយកដ្ឋានវិស្វកម្មកសិកម្ម | មន្ត្រីទទួលបន្ទុកត្រួតពិនិត្យ និងវាយតម្លៃគម្រោង |

**ប្រការ២._**

អង្គភាពគ្រប់គ្រងកម្មវិធីថ្នាក់ជាតិ (National Implementation Office-NIO) នៃកម្មវិធីអភិវឌ្ឍន៍ពាណិជ្ជកម្មស្រូវដែលធន់នឹងអាកាសធាតុ (Rice-SDP) មានភារកិច្ចអនុវត្តការងារតាមខ្លឹមសារដូចមានចែងនៅក្នុងអនុស្សរណៈនៃការយោគយល់ស្តីពីកម្មវិធីអភិវឌ្ឍន៍ពាណិជ្ជកម្មស្រូវដែលធន់នឹងអាកាសធាតុចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១២ រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី។

**ប្រការ៣ ._**

សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤ ._**

អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែ អាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ធនាគារអភិវឌ្ឍន៍អាស៊ី
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ